២០១៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

Ministry of Industry & Handicraft

លេខ: ៧០៦ MIH / ២០១៧

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ក្នុងរោងចក្រ និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៣៣ បល.ប្រក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- បានឃើញប្រកាសលេខ ១៩៨ MIH/2016 ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីនីតិវិធី និងបែបបទស្នើសុំបង្កើតរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៩៩ MIH/2016 ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីនីតិវិធីអនុវត្តបទប្បញ្ញត្តិលើកិច្ចដំណើរការរោងចក្រ និងសិប្បកម្ម
- បានឃើញប្រកាសរួមលេខ ៧១៧ សហវ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងពង្រឹងការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ក្នុងរោងចក្រ និងសិប្បកម្មឱ្យបានត្រឹមត្រូវ សំដៅរួមចំណែកធានាបាននូវសុវត្ថិភាព បរិស្ថាន និងសុខុមាលភាពសង្គម ស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ៖

- បង្កើតវិធានក្នុងការត្រួតពិនិត្យ ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យ
- បង្កើតវិធានក្នុងការត្រួតពិនិត្យកិច្ចដំណើរការនៃខ្សែសង្វាក់ផលិតកម្ម និងការងារសុវត្ថិភាពឧស្សាហកម្ម នៅក្នុងរោងចក្រ និងសិប្បកម្ម
- កំណត់ពីកាតព្វកិច្ចរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម អ្នកដំឡើង អ្នកបញ្ជា ក្នុងការទទួលខុសត្រូវ លើសុវត្ថិភាពក្នុងការប្រើប្រាស់ឧបករណ៍ គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន
- បង្កើតវិធានក្នុងការគ្រប់គ្រងបច្ចេកទេស ការត្រួតពិនិត្យ ការបង្ការអគ្គីភ័យលើការបំពាក់គ្រឿងចក្រ គ្រឿងម៉ាស៊ីន ក្នុងរោងចក្រ-សិប្បកម្ម
- បង្កើតវិធានក្នុងការត្រួតពិនិត្យការគ្រប់គ្រងបរិស្ថានឧស្សាហកម្ម។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម អ្នកដំឡើង អ្នកបញ្ជា និងសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីន ក្នុងខ្សែសង្វាក់ផលិតកម្ម ដែលអាចបង្កហានិភ័យដូចជា៖ ឡចំហាយ ម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមខ្យល់ ម៉ាស៊ីនយោង យានយន្តលើកដាក់ ឧបករណ៍លើកដាក់ ឧបករណ៍ស្ទូច និងម៉ាស៊ីន ឬឧបករណ៍ផ្សេងៗទៀតដែលអាចបង្ករការងាយឆេះ ងាយផ្ទុះ ដើម្បីអនុវត្តការធានាសុវត្ថិភាពឧស្សាហកម្ម រួមទាំងការបង្ការអគ្គីភ័យ និងសុវត្ថិភាពបរិស្ថានឧស្សាហកម្ម។

**ប្រការ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះរួមមាន៖

- **ឡចំហាយ** សំដៅលើឧបករណ៍សម្រាប់ផលិតចំហាយទឹក ដែលធន់នឹងសម្ពាធខ្ពស់។
- **ប្រព័ន្ធប្រើប្រាស់ចំហាយ** សំដៅលើប្រព័ន្ធបណ្តាញចែកចាយចំហាយ សម្រាប់ប្រើប្រាស់ក្នុងផលិតកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៤៤
អ៊ីម៉ែល: mih.smcabinet@gmail.com

- **ធុងផ្ទុកសម្ពាធខ្ពស់** សំដៅលើឧបករណ៍ផ្ទុកសម្ពាធដែលអាចបង្កឲ្យមានហានិភ័យ ដល់ការប្រើប្រាស់ក្នុងផលិតកម្ម។
- **ម៉ាស៊ីនភ្លើង** សំដៅលើឧបករណ៍ ឬម៉ាស៊ីន ដែលបំលែងពីថាមពលមេកានិកទៅជាថាមពលអគ្គិសនី។
- **ម៉ាស៊ីនបូមខ្យល់** សំដៅលើឧបករណ៍ ឬម៉ាស៊ីនបូមបំណែនខ្យល់ ដែលអាចផ្ទុកសម្ពាធបាន ដើម្បីបញ្ជូនទៅប្រើប្រាស់ក្នុងផ្នែកផ្សេងៗនៃផលិតកម្ម។
- **ម៉ាស៊ីនយោង** សំដៅលើឧបករណ៍បង្គុំចេញពីទូផ្ទុក ម៉ូទ័រ ខ្សែកាប និងប្រព័ន្ធបញ្ជាសម្រាប់យោងផលិតផល វត្ថុធាតុដើម ឧបករណ៍ និងសម្ភារផ្សេងៗ ពីជាន់ក្រោមទៅជាន់លើ ឬពីជាន់លើមកជាន់ក្រោម ក្នុងអគាររោងចក្រ-សិប្បកម្ម។
- **យានយន្តលើកដាក់** សំដៅលើយានយន្ត បំលាស់ទីក្នុងល្បឿនយឺត ដើម្បីលើកដាក់ ឬដឹកជញ្ជូនទំនិញ ឬសម្ភារផ្សេងៗក្នុងទីតាំងរោងចក្រ-សិប្បកម្ម។
- **ឧបករណ៍លើកដាក់** សំដៅលើឧបករណ៍បំលាស់ទីដោយកម្លាំងមនុស្សក្នុងល្បឿនយឺត ដើម្បីលើកដាក់ ឬដឹកជញ្ជូន ទំនិញ ឬសម្ភារផ្សេងៗក្នុងទីតាំងរោងចក្រ-សិប្បកម្ម។
- **ឧបករណ៍ស្ទូច** សំដៅដល់ឧបករណ៍យោង ឬស្ទូចផលិតផល ឧបករណ៍ ឬសម្ភារធ្ងន់ៗក្នុងទីតាំងផលិតកម្ម។
- **ខ្សែសង្វាក់ផលិតកម្ម** សំដៅដល់ប្រព័ន្ធបង្គុំ ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីន បម្រើដល់កិច្ចដំណើរការផលិតកម្ម ដែលនៅក្នុងនោះវត្ថុធាតុដើមត្រូវបានបំលែងទៅជាផលិតផលសម្រេច។
- **អ្នកបញ្ជា** សំដៅដល់អ្នកប្រតិបត្តិ ឬបញ្ជាផ្ទាល់លើឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនទៅតាមយថាប្រភេទ។
- **សុវត្ថិភាពឧស្សាហកម្ម** សំដៅដល់ការរៀបចំ ការបំពាក់ ការដំណើរការ សម្រាប់សកម្មភាព នៃកិច្ចដំណើរការរោងចក្រ និងសិប្បកម្មទាំងឡាយ ដែលបាននិងកំពុងប្រតិបត្តិការដោយមិនបង្កឱ្យមានគ្រោះថ្នាក់ និងមហន្តរាយដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន ទាំងខាងក្នុង ខាងក្រៅរោងចក្រ និងសាធារណៈ។
- **បរិស្ថានឧស្សាហកម្ម** សំដៅដល់បរិយាកាស ឬស្ថានភាពមានឥទ្ធិពលដែលបង្កដោយសកម្មភាពផលិតកម្មនៅក្នុង និងជុំវិញទីតាំងផលិតកម្ម។

## ជំពូកទី ២
## ការគ្រប់គ្រងលក្ខណៈបច្ចេកទេស

**ប្រការ៥.-**

ឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលប្រើប្រាស់ក្នុងរោងចក្រ-សិប្បកម្ម ត្រូវមានលក្ខណៈបច្ចេកទេសតាមលក្ខខណ្ឌតម្រូវ និងត្រូវមានអត្តសញ្ញាណសម្គាល់ច្បាស់លាស់ ដូចជា ម៉ូដែល ស៊េរី ប្រភេទ ទំហំ កម្លាំង សមត្ថភាពផលិត ម៉ាក សម្ពាធ កម្ពស់ ទម្ងន់ផ្ទុក ឆ្នាំផលិត ប្រទេសផលិត។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

ចំពោះឧបករណ៍ ដែលមានហានិភ័យត្រូវមានលក្ខណៈបច្ចេកទេសដូចខាងក្រោម៖

- **ឡចំហាយ** ចាំបាច់ត្រូវមានបំពាក់ឧបករណ៍សំខាន់ៗមួយចំនួនដូចជា៖ ប្រព័ន្ធបញ្ជារួម នាឡិកាវាស់សម្ពាធ ស៊ូប៉ាប់សុវត្ថិភាព កែវត្រួតពិនិត្យកម្រិតទឹក វ៉ានទឹក វ៉ានចំហាយ ឧបករណ៍ប្រកាសអាសន្ន ប្រព័ន្ធចែកចាយចំហាយ រួមទាំងឧបករណ៍ប្រព្រឹត្តិកម្មសម្អាតផ្សេង និងធូលី ក្នុងករណីឡចំហាយមិនប្រើថាមពលអគ្គីសនី ឬថាមពលស្អាត និងត្រូវដាក់ឆ្ងាយពីអគារផលិតកម្ម ដោយមានគ្រឹះចាប់ភ្ជាប់ជើងទម្រ។
- **ម៉ាស៊ីនភ្លើង** ចាំបាច់ត្រូវមានប្រព័ន្ធទប់សម្លេង រ៉ាំញ៉ូរ ឧបករណ៍ផ្ដាច់ចរន្តស្វ័យប្រវត្តិ គ្រប់ប្រព័ន្ធចែកចាយ ឧបករណ៍ម៉ាសជី និងឧបករណ៍ផ្សេងៗ។
- **យានយន្តលើកដាក់** ត្រូវមានលក្ខណៈបច្ចេកទេសចាំបាច់មួយចំនួនដូចជា៖ ចង្កៀងបំភ្លឺ ហ្វ្រាំង ភ្លើងស៊ីញ៉ូមុខក្រោយ ភ្លើងសញ្ញា កញ្ចក់ ការត្រួតពិនិត្យកង់ និងត្រួតពិនិត្យប្រព័ន្ធលើកដាក់។
- **ឧបករណ៍ស្ទូច** ត្រូវមានលក្ខណៈបច្ចេកទេសចាំបាច់មួយចំនួនដូចជា៖ ខ្សែកាប ម៉ូទ័រយោងកាប និងប្រអប់ទូបញ្ជា។
- **ប្រព័ន្ធប្រើប្រាស់ចំហាយ** ត្រូវមានលក្ខណៈបច្ចេកទេសចាំបាច់មួយចំនួនដូចជា៖ នាឡិកាវាស់សម្ពាធ អ៊ីសូឡង់ការពារការចម្លងកម្ដៅ វ៉ានបិទបើក និងឧបករណ៍ដកទឹកនិងខ្យល់។
- **ឧបករណ៍ ឬធុងដែលប្រើសម្ពាធខ្ពស់** ត្រូវមានឧបករណ៍ចាំបាច់មួយចំនួនដូចជា៖ នាឡិកាវាស់សម្ពាធ វ៉ានសុវត្ថិភាព និងត្រូវមានការកំណត់កាលបរិច្ឆេទប្រើប្រាស់ច្បាស់លាស់។

### ប្រការ៦._

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវទទួលខុសត្រូវលើសុវត្ថិភាពនៃការប្រើប្រាស់ឧបករណ៍ គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន និងចាត់តាំងឱ្យមានអ្នកទទួលបន្ទុកគ្រប់គ្រងការប្រើប្រាស់ឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនរបស់ខ្លួន។ អ្នកដំឡើង អ្នកបញ្ជា និងអ្នកទទួលបន្ទុកគ្រប់គ្រងចាំបាច់ត្រូវមានជំនាញច្បាស់លាស់ ដែលទទួលស្គាល់ដោយសមត្ថកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

អ្នកបញ្ជាឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនត្រូវមានកាយសម្បទាគ្រប់គ្រាន់ មានការទទួលខុសត្រូវខ្ពស់ និងចាំបាច់ត្រូវឆ្លងកាត់វគ្គបណ្ដុះបណ្ដាលជំនាញបច្ចេកទេសច្បាស់លាស់ ដែលទទួលស្គាល់ដោយសមត្ថកិច្ចក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

### ប្រការ៧._

អ្នកទទួលបន្ទុកគ្រប់គ្រងការប្រើប្រាស់ឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនត្រូវមានកម្មវិធីថែទាំ ជួសជុលទៅតាមកាលវិភាគមួយដែលត្រូវបានកំណត់ឡើងទៅតាមរយៈពេលថែទាំ ជួសជុល ច្បាស់លាស់។ ការថែទាំតម្រូវឱ្យអនុវត្តតាមនីតិវិធីដែលអនុលោមតាមបច្ចេកទេសយថាប្រភេទតាមឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីននីមួយៗ ដូចជាការត្រួតពិនិត្យ ការជួសជុល ការកែលម្អ ការលាងសម្អាតក្នុង និងក្រៅឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

## ជំពូកទី ៣
## សុវត្ថិភាពឧស្សាហកម្មលើ ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលមានហានិភ័យ

**ប្រការ៨.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មត្រូវរៀបចំឱ្យមានស្លាកសញ្ញាសុវត្ថិភាពជាភាសាខ្មែរ រួមមាន៖

- **ស្លាកសញ្ញាបង្ហាញ៖** ដូចជា រអិល ផ្លូវបញ្ចៀស ផ្លូវចេញ ផ្លូវចូល បត់ស្តាំ បត់ឆ្វេង ផែនទីបង្ហាញ គំនូសបង្ហាញទីតាំង និងស្លាកសញ្ញាចាំបាច់មួយចំនួនទៀត
- **ស្លាកសញ្ញាហាមឃាត់៖** ដូចជា គ្មានភារកិច្ចហាមចូល ហាមប៉ះ ហាមជក់បារី និងស្លាកសញ្ញាចាំបាច់មួយចំនួនទៀត
- **ស្លាកសញ្ញាបញ្ជា៖** ដូចជា បទបញ្ជាបច្ចេកទេស និងសុវត្ថិភាព និងស្លាកសញ្ញាចាំបាច់ មួយចំនួនទៀត
- **ស្លាកសញ្ញាព្រមាន៖** ដូចជា គ្រោះថ្នាក់ដល់ជីវិត ពុលខ្លាំង ប៉ះពាល់សុខភាព ឆាបឆេះ ផ្ទុះ ប្រយ័ត្ន អគ្គីភ័យ និងស្លាកសញ្ញាចាំបាច់មួយចំនួនទៀត។

**ប្រការ៩.-**

ឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលមានហានិភ័យ ត្រូវមានទីតាំងដំឡើង និងទុកដាក់ត្រឹមត្រូវច្បាស់លាស់ ដូចជា អគារ បន្ទប់ រោង ត្រូវមានទំហំធំទូលាយ និងមានសណ្តាប់ធ្នាប់ល្អ។ ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីន ឬផ្នែករបស់វា ត្រូវមានរបាំងការពារ គម្រប ឬឧបករណ៍ការពារ របាំងព័ទ្ធជុំវិញដាច់ដោយឡែក និងត្រូវមានគំនូសបង្ហាញ ដោយដាក់ឈ្មោះតាមយថាប្រភេទ។

**ប្រការ១០.-**

អ្នកបញ្ជាឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីនត្រូវប្រើប្រាស់ឧបករណ៍ការពារសុវត្ថិភាព ដូចជា មួកសុវត្ថិភាព ម៉ាសសុវត្ថិភាព វ៉ែនតាសុវត្ថិភាព ស្រោមដៃសុវត្ថិភាព ស្បែកជើងសុវត្ថិភាព សម្លៀកបំពាក់ការពារសុវត្ថិភាព ឧបករណ៍ការពារត្រចៀក ទៅតាមស្ថានភាព និងផលប៉ះពាល់ជាក់ស្តែង។

## ជំពូកទី ៤
## ការបង្ការអគ្គីភ័យក្នុងរោងចក្រ-សិប្បកម្ម

**ប្រការ១០.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ពេលរៀបចំបំពាក់គ្រឿងចក្រ គ្រឿងម៉ាស៊ីន ឧបករណ៍ ដែលជាសង្វាក់ផលិតកម្ម មាន កិនបំបែក បំផ្លែង បន្សុទ្ធ ត្រូវមានគំនូសប្លង់ រៀបចំប្រព័ន្ធ គ្រឿងចក្រ គ្រឿងម៉ាស៊ីន ផ្គូបជាមួយលក្ខណៈបច្ចេកទេសបង្ការអគ្គីភ័យ ក្នុងគោលដៅសុវត្ថិភាពឧស្សាហកម្មក្នុងផលិតកម្ម ដោយអនុវត្តតាមលក្ខណៈបច្ចេកទេសសំខាន់ៗជាអាទិ៍៖

- គ្រឿងចក្រ គ្រឿងម៉ាស៊ីនត្រូវរៀបចំតាមប្រព័ន្ធបច្ចេកទេសដែលបានកំណត់
- ប្រព័ន្ធប្រកាសអាសន្ន និងអ្នកទទួលខុសត្រូវច្បាស់លាស់

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែល: mih.smcabinet@gmail.com

- មធ្យោបាយចាំបាច់សម្រាប់ពន្លត់អគ្គីភ័យ
- សញ្ញាប្រយ័ត្នអគ្គីភ័យមានដាក់បង្ហាញនៅកន្លែងសំខាន់ៗដែលមានលក្ខណៈហានិភ័យក្នុងការបង្កការងាយឆេះងាយផ្ទុះ
- ការរៀបចំមធ្យោបាយរំដោះខ្លួននៅពេលមានអាសន្ន
- ប្លង់គំនូសបំព្រួញសម្រាប់ជម្លៀសខ្លួនពេលមានអាសន្ន
- គំនូសផ្លូវសម្រាប់រថយន្តពន្លត់អគ្គីភ័យចូលទៅដល់ទីតាំង។

**ប្រការ១១.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មត្រូវមានគំនូសប្លង់បង្ហាញសម្រាប់ អគារ ទីកន្លែង ឬយានយន្តសម្រាប់ផលិត បំផ្លែងវត្ថុធាតុដើម ឬផលិតផលសម្រេចទៅជាផលិតផលថ្មី ឬ និងសម្រាប់ធ្វើសកម្មភាពផ្សេងៗដែលមានជាអាទិ៍៖ ផ្គុំ ដំឡើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ច្រកបំពេញ ថែទាំ រក្សាទុក កែលម្អ សម្រាប់បម្រើដល់ការផលិត និងទីផ្សារ ក្នុងការរៀបចំអគារ ទីកន្លែងខាងលើ ត្រូវមានបង្ហាញក្នុងប្លង់សុវត្ថិភាពបង្ការអគ្គីភ័យស្របតាមលក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម។

**ប្រការ១២.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ចាំបាច់ត្រូវរៀបចំបំពាក់ប្រព័ន្ធពន្លត់អគ្គីភ័យដូចជា៖ បង្គោលទឹកសម្រាប់រថយន្តពន្លត់អគ្គីភ័យ បំពង់ពន្លត់អគ្គីភ័យ ឧបករណ៍ស្រូបផ្សែងប្រកាសអាសន្ន ឧបករណ៍ប្រើសម្រាប់វាយបំបែក ប្រព័ន្ធបំពង់ទឹក ទុយោ ក្បាលបាញ់ ម៉ូទ័របូម ប្រព័ន្ធពន្លត់ស្វ័យប្រវត្តិ អាងស្តុកទឹកបម្រុង ទៅតាមលក្ខណៈបច្ចេកទេស។

**ប្រការ១៣.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវរៀបចំឲ្យមានកម្មវិធី ការពារគ្រោះអន្តរាយផ្សេងៗបង្កដោយយថាហេតុមានជាអាទិ៍៖ បរិយាកាសផលិតកម្មមិនស្អាត ការបង្កគ្រោះអគ្គីភ័យ ការបញ្ចេញសំណល់ឧស្សាហកម្មដែលធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពបុគ្គលិក កម្មករ ក្នុងរោងចក្រ សិប្បកម្ម ដោយហ្វឹកហាត់ និងចាត់តាំងច្បាស់លាស់ដល់និយោជិត និងកម្មករប្រចាំការ។

**ប្រការ១៤.-**

ចំពោះសហគ្រាសធុនតូច និងសិប្បកម្ម អាចលើកលែងលក្ខខណ្ឌបច្ចេកទេសខ្លះក្នុងការបង្ការអគ្គីភ័យសមស្របនឹងលក្ខណៈទីតាំង រោងចក្រផលិតកម្មទៅតាមស្ថានភាពជាក់ស្តែង។

## ជំពូកទី ៥
## ការគ្រប់គ្រងបរិស្ថានឧស្សាហកម្ម

**ប្រការ១៥.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម នៅពេលរៀបចំដំណើរការផលិតកម្ម ត្រូវរៀបចំការការពារបរិស្ថាន ក្នុងនោះមាន សំណល់ឧស្សាហកម្មគ្រប់ប្រភេទមុននឹងបញ្ចេញចោលត្រូវឆ្លើយតបទៅនឹងកម្រិតបទដ្ឋាន



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីមែល: mih.smcabinet@gmail.com

នៃការបញ្ចេញសំណល់ ឬសារធាតុពុលដែលកំណត់ដោយបទប្បញ្ញត្តិរបស់ស្ថាប័នមានសមត្ថកិច្ច។ ការបញ្ចេញបោលសំណល់ឧស្សាហកម្មដែលមានជាតិពុល ឬសារធាតុពុលដែលនាំឱ្យកខ្វក់ ម្ចាស់រោងចក្រ និងសិប្បកម្មត្រូវធ្វើប្រព្រឹត្តិកម្មជាមុន។ ចំពោះសំណល់ឧស្សាហកម្ម ដែលត្រូវយកមកប្រើប្រាស់ឡើងវិញ ត្រូវរក្សាទុកឱ្យបានគត់មុតតាមយថាប្រភេទ។ ក្នុងករណីសំណល់ឧស្សាហកម្មក្រោយពីបានធ្វើប្រព្រឹត្តិកម្មរួច ពិនិត្យឃើញថានៅមានសារធាតុពុលមិនអាចយកមកប្រើប្រាស់ ឬកែច្នៃ ការវេចខ្ចប់ ការដឹកជញ្ជូនត្រូវមានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច ហើយម្ចាស់រោងចក្រ សិប្បកម្ម ត្រូវទទួលខុសត្រូវ អំពីបរិស្ថាន ឬសំណល់ឧស្សាហកម្មទាំងនោះ។

**ប្រការ១៦.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវរៀបចំឱ្យមានរបាយការណ៍អំពីប្រភេទសំណល់ និងបរិមាណសំណល់ឧស្សាហកម្មច្បាស់លាស់ ដែលបានបញ្ចេញក្នុងមួយឆ្នាំៗ។

លក្ខណៈបច្ចេកទេសក្នុងការទុកដាក់ ឬស្តុកទុកបណ្តោះអាសន្ន និងលក្ខណៈបច្ចេកទេសក្នុងការសម្អាតសំណល់ ឬប្រព្រឹត្តិកម្មសំណល់ក្នុងរោងចក្រ-សិប្បកម្ម ត្រូវមានការត្រួតពិនិត្យ វាយតម្លៃដោយមន្ត្រីជំនាញក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយសហការជាមួយក្រសួង ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្អែកតាមសំណូមពរការងារចាំបាច់។

**ប្រការ១៧.-**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើកទឹកចិត្តដល់រោងចក្រ និងសិប្បកម្មឱ្យមានការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់ឧស្សាហកម្មគ្រប់ប្រភេទ ជំរុញការអនុវត្តឧស្សាហកម្មបៃតង ឬការផ្ទេរបច្ចេកវិទ្យាដែលអំណោយផលដល់បរិស្ថាន។

## ជំពូកទី ៦
## ភារកិច្ចរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម

**ប្រការ១៨.-**

មុនចាប់ផ្តើមដំណើរការឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មត្រូវស្នើសុំវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ វិញ្ញាបនបត្រនេះផ្តល់ឲ្យចំពោះតែឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន និងលក្ខណៈបច្ចេកទេសការគ្រប់គ្រងសំណល់ឧស្សាហកម្មទាំងឡាយណាដែលមានលក្ខណៈសមស្រប និងអនុលោមតាមបទដ្ឋានបច្ចេកទេស។

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវរៀបចំបំពេញបែបបទស្នើសុំវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ត្រូវបង់ប្រាក់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្មតាមការកំណត់តម្លៃសេវាសាធារណៈ រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មន្ត្រីជំនាញរបស់ក្រសួងនឹងចុះទៅត្រួតពិនិត្យវាយតម្លៃលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម មុននឹងចេញជូនវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៤៤
អ៊ីម៉ែល: mih.smcabinet@gmail.com

**ប្រការ១៩.-**

វិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស សុវត្ថិភាពឧស្សាហកម្មមានសុពលភាពមួយឆ្នាំ។ ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ត្រូវធ្វើការស្នើសុំឡើងវិញយ៉ាងតិច៣០(សាមសិប)ថ្ងៃ មុនផុតសុពលភាព ដើម្បីមន្ត្រីជំនាញនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះត្រួតពិនិត្យ វាយតម្លៃលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្មឡើងវិញ។

**ប្រការ២០.-**

ការកំណត់តម្លៃសេវាសាធារណៈ ពាក់ព័ន្ធនឹងការស្នើសុំវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្មត្រូវអនុលោមទៅតាមប្រកាសរួមរវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ២១.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្មត្រូវផ្តល់កិច្ចសហការល្អជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងពេលចុះត្រួតពិនិត្យ វាយតម្លៃដើម្បីចេញវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម។

វិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ត្រូវដាក់តាំងបង្ហាញនៅទីតាំងឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលអាចឱ្យមន្ត្រី ឬភ្នាក់ងារមានសមត្ថកិច្ចងាយមើលឃើញ។

**ប្រការ២២.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ឬជនណា ដែលប្រើឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្សត្រូវទទួលទោសតាមច្បាប់ជាធរមាន។

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ-សិប្បកម្ម ឬជនណា ដែលប្រើឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យ ហើយមិនព្រមសុំវិញ្ញាបនបត្របញ្ជាក់លក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម ត្រូវទទួលទោសតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២៣.-**

ប្រកាសលេខ ១៥២ MIH/២០១៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងលក្ខណៈបច្ចេកទេស និងសុវត្ថិភាពឧស្សាហកម្ម លើឧបករណ៍ ឬគ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលមានហានិភ័យ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ២៤.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ប្រធាននាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា គ្រប់អង្គភាពពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងបរិស្ថាន
-ក្រសួងស្ថាប័នពាក់ព័ន្ធ
-សាលារាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-ដូចប្រការ២៤
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីមែល: mih.smcabinet@gmail.com